# សេចក្ដីណែនាំស្ដីពីការបំពេញទិន្នន័យ
# ក្នុងបញ្ជីកត់ត្រាជំងឺសម្រាកពេទ្យផ្នែកជំងឺទូទៅ

*បោះពុម្ពលើកទី១, ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៣*

កំណត់សម្គាល់ ៖

- បញ្ជីកត់ត្រានេះត្រូវប្រើនៅសាលជំងឺសម្រាកពេទ្យផ្នែកជំងឺទូទៅ សម្រាប់កត់ត្រាអ្នកជំងឺសម្រាកពេទ្យទូទៅ។
- បិទបញ្ជីនៅថ្ងៃចុងក្រោយនៃខែនីមួយៗ។
- សម្រាប់ខែថ្មី កាលបរិច្ឆេទត្រូវសរសេរនៅចំកណ្ដាលទំព័រថ្មីនៃសៀវភៅកត់ត្រា។

ត្រូវបំពេញព័ត៌មានលម្អិតនៅបន្ទាត់ (ជួរផ្ដេក) តាមការណែនាំខាងក្រោមនូវគ្រប់ករណីទាំងអស់ ៖

| ខ្ទង់ទី | សេចក្ដីណែនាំ |
|---|---|
| ១ | *លេខរៀង*<br>ជាលេខរៀង(លេខស្ទឹត)តាមលំដាប់។ លេខរៀងនេះត្រូវចាប់ផ្ដើមពីលេខ ១ និងលេខបន្តបន្ទាប់រហូតដល់ដាច់ខែ។ ចាប់ផ្ដើមលេខរៀងថ្មី(លេខស្ទឹត)នៅរៀងរាល់ខែថ្មី។ |
| ២ | *លេខកូដអ្នកជំងឺ*<br>ត្រូវចម្លងលេខពីលេខកូដអ្នកជំងឺរបស់មន្ទីរពេទ្យ។ ឧទាហរណ៍៖ 000-000-123-1។ |
| ៣ | *ឈ្មោះអ្នកជំងឺ*<br>សរសេរឈ្មោះពេញ (នាមត្រកូល និងនាមខ្លួន) របស់អ្នកជំងឺដែលមកសម្រាកពេទ្យ។ |
| ៤ | *អាយុ៖ ១៥-២៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្ដែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ១៥ឆ្នាំ រហូតដល់ ២៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ២០ឆ្នាំ សរសេរ ២០។ |
| ៥ | *អាយុ៖ ២៥-៤៩ ឆ្នាំ*<br>សរសេរអាយុជាក់ស្ដែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ២៥ឆ្នាំ រហូតដល់ ៤៩ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៣៥ឆ្នាំ សរសេរ ៣៥។ |
| ៦ | *អាយុ៖ ៥០-៦៤ ឆ្នាំ*<br>សរសេរអាយុជាក់ស្ដែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ៥០ឆ្នាំ រហូតដល់ ៦៤ឆ្នាំ។ ឧទាហរណ៍៖ អាយុ ៥៥ឆ្នាំ សរសេរ ៥៥។ |
| ៧ | *អាយុ៖ ≥៦៥ ឆ្នាំ*<br>សរសេរអាយុជាក់ស្ដែង ប្រសិនបើអ្នកជំងឺមានអាយុចាប់ពី ៦៥ឆ្នាំ ឡើងទៅ។ ឧទាហរណ៍៖ អាយុ ៦៦ឆ្នាំ សរសេរ ៦៦។ |
| ៨ | *ភេទ៖ ប្រុស*<br>សរសេរលេខរៀង(លេខស្ទឹត)តាមលំដាប់ ប្រសិនបើអ្នកជំងឺភេទប្រុស។<br>ឧទាហរណ៍៖ ១, ២, ៣... |
| ៩ | *ភេទ៖ ស្រី*<br>សរសេរលេខរៀង(លេខស្ទឹត)តាមលំដាប់ ប្រសិនបើអ្នកជំងឺភេទស្រី។<br>ឧទាហរណ៍៖ ១, ២, ៣... |

| ខ្ទង់ទី | សេចក្តីណែនាំ |
|---|---|
| ១០ | *<u>អាស័យដ្ឋានបច្ចុប្បន្ន និងលេខទូរស័ព្ទ</u>*<br>សរសេរអាស័យដ្ឋានបច្ចុប្បន្នរបស់អ្នកជំងឺដែលមកទទួលសេវាមន្ទីរពេទ្យ។ ត្រូវសរសេរភូមិ ឃុំ/សង្កាត់ ស្រុក/ក្រុង/ខណ្ឌ រាជធានី/ខេត្ត និងលេខទូរស័ព្ទ។ |
| ១១ | *<u>បញ្ជូនមកពី</u>*<br>សរសេរឈ្មោះទីកន្លែងដែលបានបញ្ជូនអ្នកជំងឺមក។<br>ឧទាហរណ៍៖ មណ្ឌលសុខភាព ខ។ |
| ១២ | *<u>រោគវិនិច្ឆ័យចូល</u>*<br>សរសេររោគវិនិច្ឆ័យចូលដែលគ្រូពេទ្យបានកំណត់។ |
| ១៣ | *<u>ថ្ងៃខែឆ្នាំចាប់ផ្តើមឈឺ</u>*<br>សរសេរថ្ងៃខែឆ្នាំ ដែលអ្នកជំងឺចាប់ផ្តើមឈឺ (មុនពេលមកមន្ទីរពេទ្យលើកនេះ)។<br>ឧទាហរណ៍៖ អ្នកជំងឺចូលសម្រាកពេទ្យថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៣ ប៉ុន្តែចាប់ផ្តើមឈឺនៅថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៣ *ត្រូវសរសេរ ០៥/០១/២០១៣* ។ |
| ១៤ | *<u>ថ្ងៃខែឆ្នាំ/ម៉ោងចូល</u>*<br>សរសេរថ្ងៃខែឆ្នាំ ដែលអ្នកជំងឺចាប់ផ្តើមចូលសម្រាកពេទ្យ។<br>ឧទាហរណ៍៖ អ្នកជំងឺចូលសម្រាកពេទ្យថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៣ ម៉ោង២៣.០០ ត្រូវសរសេរ ១០/០១/២០១៣ ម៉ ២៣.០០ ។ |
| ១៥ | *<u>អមវេជ្ជសាស្ត្រ</u>*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើគ្រូពេទ្យស្នើសុំសេវាអមវេជ្ជសាស្ត្រ។ ឧទាហរណ៍៖ ១, ២, ៣... |
| ១៦ | *<u>ថ្ងៃខែឆ្នាំ/ម៉ោងចេញ</u>*<br>សរសេរថ្ងៃខែឆ្នាំ/ម៉ោង ដែលអ្នកជំងឺបានចេញពីមន្ទីរពេទ្យ។<br>ឧទាហរណ៍៖ អ្នកជំងឺចេញពីមន្ទីរពេទ្យនៅថ្ងៃទី ១៤ ខែមករា ឆ្នាំ២០១៣ ម៉ោង១៥.០០ *ត្រូវសរសេរ ១៤/០១/២០១៣ ម៉ ១៥.០០*។ |
| ១៧ | *<u>រោគវិនិច្ឆ័យចេញ</u>*<br>សរសេររោគវិនិច្ឆ័យចេញនៅពេលអ្នកជំងឺចេញពីមន្ទីរពេទ្យ។ |
| ១៨ | *<u>មរណភាពមាតា</u>*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើមានករណីម្តាយស្លាប់កំឡុងពេលមានផ្ទៃពោះ/សម្រាលកូន និង ៤២ថ្ងៃក្រោយសម្រាលកូន (សរសេរមូលហេតុស្លាប់នៅក្នុងខ្ទង់សម្គាល់)។ ឧទាហរណ៍៖ ១, ២, ៣... |
| ១៩ | *<u>ទម្រង់នៃអ្នកជំងឺចេញ៖ អនុញ្ញាត</u>*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺត្រូវបានអនុញ្ញាតអោយចេញពីមន្ទីរពេទ្យ។<br>ឧទាហរណ៍៖ ១, ២, ៣... |
| ២០ | *<u>ទម្រង់នៃអ្នកជំងឺចេញ៖ មិនអនុញ្ញាត</u>*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺបានចេញពីមន្ទីរពេទ្យដោយគ្មានការអនុញ្ញាត ឬស្នើសុំចេញពីមន្ទីរពេទ្យដោយករណីផ្សេងៗ (អ្នកជំងឺត្រូវបានស្នើសុំទៅព្យាបាលនៅផ្ទះ ឬកន្លែងផ្សេងទៀតដោយស្ថានភាពជំងឺពុំទាន់បានធូរស្រាល)។ ឧទាហរណ៍៖ ១, ២, ៣... |
| ២១ | *<u>ទម្រង់នៃអ្នកជំងឺចេញ៖ បញ្ជូន</u>*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺត្រូវបានបញ្ជូនចេញពីមន្ទីរពេទ្យ ឬទៅកាន់មូលដ្ឋានសុខាភិបាលណាផ្សេង (សរសេរឈ្មោះមូលដ្ឋានសុខាភិបាល/សេវាឯកជនផ្សេងៗនៅក្នុងខ្ទង់សម្គាល់)។<br>ឧទាហរណ៍៖ ១, ២, ៣... |

| ខ្ទង់ទី | សេចក្ដីណែនាំ |
|---|---|
| ២២ | *ទម្រង់នៃអ្នកជំងឺចេញ៖ ស្លាប់*<br>សរសេរលេខរៀង(លេខស្ទីត)តាមលំដាប់ ប្រសិនបើអ្នកជំងឺស្លាប់។<br>ឧទាហរណ៍៖ ១, ២, ៣...<br>*ចំណាំ៖ ទោះបីជាមានរាយការណ៍ក្នុងខ្ទង់មរណភាពមាតាក៏ដោយ។* |
| ២៣ | *មូលហេតុស្លាប់*<br>សរសេរមូលហេតុផ្សេងៗ ដែលទាក់ទងទៅនឹងការស្លាប់របស់អ្នកជំងឺ។ |
| ២៤ | *ស្ថានភាពអ្នកជំងឺពេលចេញ*<br>សរសេរលេខកូដសម្រាប់ស្ថានភាពចេញរបស់អ្នកជំងឺដែលបានចេញពីមន្ទីរពេទ្យទោះបីក្នុងករណី អនុញ្ញាត មិនអនុញ្ញាត បញ្ជូន ឬស្លាប់។<br>(១) ជាសះស្បើយ (២) ធូរស្រាល (៣) មិនមានការធូរស្រាល (៤) រិតតែធ្ងន់ធ្ងរ និង (៥) អស់សង្ឃឹម + ស្ថានភាពពិការដោយសារផលវិបាកនៃជំងឺ ឬគ្រោះថ្នាក់ផ្សេងៗ យកតែករណីសម្រាកពេទ្យលើកនេះប៉ុណ្ណោះ (A1=ពិការកាយសម្បទា, A2=ពិការសតិបញ្ញា, A3=ពិការផ្លូវចិត្ត, A4=ពិការផ្សេងៗ)។<br>ឧទាហរណ៍៖ ជាសះស្បើយ និងពិការកាយសម្បទា = ១A1<br>*សម្គាល់៖ សូមមើលប្រកាសអន្តរក្រសួង ស្ដីពីការកំណត់លក្ខណវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព របស់ក្រសួងសុខាភិបាលចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ នៅក្នុងឧបសម្ព័ន្ធនៃមគ្គុទេសន៍ណែនាំសម្រាប់ការបណ្ដុះបណ្ដាលស្ដីពីការប្រើប្រាស់បញ្ជីកត់ត្រាផ្នែកប្រព័ន្ធព័ត៌មានសុខាភិបាល ឬចូលទៅកាន់ Menu ការផ្សព្វផ្សាយនៃគេហទំព័រ www.hiscambodia.org។* |
| ២៥ | *ចំនួនថ្ងៃសម្រាកពេទ្យ*<br>សរសេរចំនួនថ្ងៃពិតប្រាកដដែលអ្នកជំងឺបានសម្រាកពេទ្យ។<br>ឧទាហរណ៍៖ ចូលសម្រាកពេទ្យថ្ងៃទី ០៥/០១/២០១៣ ហើយចេញពីមន្ទីរពេទ្យថ្ងៃទី ១០/០១/២០១៣ ដូច្នេះចំនួនថ្ងៃសម្រាកពេទ្យគឺ ០៦ថ្ងៃ (យកថ្ងៃចេញ ដក ថ្ងៃចូល បូកនិង ១) *ត្រូវសរសេរលេខ ០៦។*<br>និយមន័យសម្រាកពេទ្យ៖ គឺអ្នកជំងឺដែលគ្រូពេទ្យបានអនុញ្ញាតអោយសម្រាកពេទ្យនៅសាល/អគារ ដោយមិនគិតពីពេលវេលា។ |
| ២៦ | *ប្រភេទនៃការបង់ថ្លៃសេវា*<br>1. សរសេរ P: សម្រាប់ការបង់លុយដោយខ្លួនឯង។<br>2. សូមសរសេរ HEF: សម្រាប់ការបង់ដោយគំរោងមូលនិធិសមធម៌។<br>3. សូមសរសេរ CBHI: សម្រាប់ការបង់ដោយគំរោងធានារ៉ាប់រងសហគមន៍។<br>4. សូមសរសេរ V(Voucher): ប្រសិនបើគាត់មានប័ណ្ណសុខភាព។<br>5. សូមសរសេរ E: សម្រាប់ករណីលើកលែង។<br>*ចំណាំ៖ រាល់ការបង់ថ្លៃសេវាដោយ HEF ឬ CBHI ឬ V សូមសរសេរលេខកូដដែលស្រង់ចេញពីប័ណ្ណនោះក្នុងខ្ទង់សម្គាល់។* |
| ២៧ | *សម្គាល់*<br>សរសេរចំនុចសម្គាល់ផ្សេងៗ ដែលចាំបាច់ទាក់ទងទៅនឹងអ្នកជំងឺ។ |

# សម្រង់តួលេខប្រចាំថ្ងៃ ជំងឺសម្រាកពេទ្យផ្នែកជំងឺទូទៅ

| នៃខែ..............ឆ្នាំ............. | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| រោគវិនិច្ឆ័យ | អាយុ Group | ករណី | ភេទ | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 | 31 | Total |
| (សរសេររោគវិនិច្ឆ័យ) | (សរសេរក្រុមអាយុ) | ឈឺ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | ស្លាប់ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ខ. គ្រុនពោះវៀន | 15-24 ឆ្នាំ | ឈឺ | ប្រុស | 1 | 1 | 1 | | | 2 | 2 | 2 | 1 | | | 1 | 1 | 1 | | 2 | 2 | 2 | 2 | | | | 1 | 1 | 1 | 1 | 1 | 1 | | | | មិនបាច់បំពេញ |
| | | | ស្រី | | 1 | 1 | 1 | 1 | | | | 1 | 1 | 1 | | | 1 | 1 | | | | | | | | | | | | | | | | | |
| | | ស្លាប់ | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | បញ្ជូនទៅ | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | HEF: បង់ដោយមូលនិធិសមធម៌ | | ប្រុស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| | | | ស្រី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |